# ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា

## ជំពូក ៤
## ការរក្សាទុក ការដឹកជញ្ជូន និង
## ការប្រើប្រាស់រំសេវផ្ទុះ

---

អគ្គលេខាធិការដ្ឋាន
អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
អគារថ្មីផ្លូវលេខ ២៧៣ កែង ៥១៦ សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ ក្រុងភ្នំពេញ
ទូរស័ព្ទលេខ: ០២៣-៨៨៥-៩៤១ | ០២៣-៨៨១-៤៩២
គេហទំព័រ: www.cmaa.gov.kh

# មាតិកា


-មាតិកា........................................................................................................២
-សេចក្តីផ្តើម....................................................................................................៤
-ការរក្សាទុក ការដឹកជញ្ជូន និង ការប្រើប្រាស់រំសេវផ្ទុះ ........................................................៥
១. ទ្រង់ទ្រាយ.....................................................................................................៥
២. វាក្យស័ព្ទ និង និយមន័យ.....................................................................................៥
៣. តម្រូវការទូទៅ..................................................................................................៥
៤. តម្រូវការបរិស្ថាន...............................................................................................៦
៥. តម្រូវការនៃការរក្សាទុក ......................................................................................៦
៥.១.ការរៀបចំឃ្លាំង ...............................................................................................៦
៥.២.សញ្ញាហាមឃាត់ និង រូបសម្គាល់...........................................................................៧
៥.៣.វិធានការបង្ការអគ្គីភ័យ .....................................................................................៧
៥.៤.តារាងចម្ងាយសុវត្ថិភាព......................................................................................៧
៥.៥.ការរៀបចំបន្ទប់ក្នុងឃ្លាំង ....................................................................................៧
៦. តម្រូវការផ្នែកដឹកជញ្ជូន ......................................................................................៧
៦.១.ទូទៅ ............................................................................................................៧
៦.២.អ្នកដំណើរ.....................................................................................................៨
៦.៣.ការដឹកជញ្ជូនគីប និង រំសេវផ្ទុះ ...........................................................................៨
៦.៤.ឧបករណ៍ពិសេស..............................................................................................៨
៧. ការប្រើប្រាស់ ...................................................................................................៨
៨. គ្រាប់និចល គ្រាប់សម្រាប់ហ្វឹកហាត់ ឬ គ្រាប់មីន និង រំសេវសិប្បនិម្មិត.......................................៨
៩. សន្តិសុខប្រចាំការ ..............................................................................................៩
១០. ការទទួលខុសត្រូវ និង កាតព្វកិច្ច...........................................................................៩
១០.១.អាជ្ញាធរមីន ...................................................................................................៩
១០.២.ប្រតិបត្តិករដោះមីន.........................................................................................១០
១០.៣.អ្នកដោះមីន .................................................................................................១០
ឧបសម្ព័ន្ធ ក (ជាព័ត៌មាន) តម្រូវការទូទៅសម្រាប់សាងសង់ឃ្លាំង.............................................១១
១.សំណង់អចិន្ត្រៃយ៍ ............................................................................................១១
២.ឃ្លាំងចល័ត ឬ ឃ្លាំងដែលអាចលើកដាក់បាន.................................................................១២
៣.ប្រអប់ប្រចាំថ្ងៃ ...............................................................................................១២
៤.ការដឹកជញ្ជូនកុងទីន័រដាក់គីប ..............................................................................១៣

៥.ការរៀបចំឃ្លាំងនៅការដ្ឋានដោះមីន ........ ១៣
ឧបសម្ព័ន្ធ ខ (ជាព័ត៌មាន) វិធានការបង្ការអគ្គីភ័យ ........ ១៥
ឧបសម្ព័ន្ធ គ (ជាព័ត៌មាន) តារាងចម្ងាយសុវត្ថិភាពសម្រាប់រៀបចំឃ្លាំងគ្រឿងផ្ទុះ ........ ១៧
ឧបសម្ព័ន្ធ ឃ (ជាធម្មតា) គ្រាប់និចល គ្រាប់សម្រាប់ហ្វឹកហាត់ ឬ គ្រាប់មីន និង រំសេវសប្បនិម្មិត ........ ២០
១.ទូទៅ ........ ២០
២.ការរក្សាទុក ........ ២០
៣.ចលនា ........ ២១
៤.ការដោះបំបែកគ្រាប់មីន និង គ្រាប់រំសេវ ........ ២១
៥.ការដាក់ផ្លាកសញ្ញាសម្គាល់គ្រាប់មីន និង គ្រាប់រំសេវនិចល ........ ២២
៦.ការចុះបញ្ជី ការរាប់ចំនួនគ្រាប់មីន និង គ្រាប់រំសេវនិចលសម្រាប់ហាត់រៀន ........ ២៣
៧.លិខិតបញ្ជាក់ពីគ្រាប់ដែលពុំមានរំសេវផ្ទុះ ........ ២៤

# សេចក្តីផ្តើម

តម្រូវការនៃការកាត់បន្ថយគ្រោះថ្នាក់ និងការផ្តល់បរិយាកាសការងារប្រកបដោយសុវត្ថិភាព គឺជាគោលការណ៍គ្រឹះនៃការគ្រប់គ្រងកិច្ចការដោះមីន នឹងត្រូវចងក្រងនៅពេលខាងមុខ ។

បញ្ញត្តិនៃបរិយាកាសសុវត្ថិភាពការងាររួមមាន ការរៀបចំឃ្លាំង ការដឹកជញ្ជូន ការប្រើប្រាស់រំសេវផ្ទុះ និងសម្ភារៈគ្រឿងផ្ទុះ ដោយសុវត្ថិភាព ព្រមទាំងតម្រូវការនូវមធ្យោបាយសមស្រប ដើម្បីរៀបចំឃ្លាំងសម្ភារៈ និងរថយន្ត ។ អាជ្ញាធរមីន និងប្រតិបត្តិករដោះមីន ត្រូវរៀបចំថែទាំគោលការណ៍ច្បាប់ និងនីតិវិធី ឲ្យបានសមស្រប ។

ស្តង់ដានេះផ្តល់ឲ្យអាជ្ញាធរមីន និងប្រតិបត្តិករដោះមីន នូវគោលការណ៍ណែនាំស្តីពីការរៀបចំឃ្លាំង ការដឹកជញ្ជូន ការប្រើប្រាស់រំសេវផ្ទុះ និងសម្ភារៈគ្រឿងផ្ទុះ ប្រកបដោយសុវត្ថិភាព ។

ត្រូវត្រៀមលក្ខណៈឲ្យបានស្រេចចំពោះកិច្ចប្រតិបត្តិការដោះមីន ព្រោះក្នុងកាលៈទេសៈខ្លះ លក្ខខ័ណ្ឌដែលសមស្រប សម្រាប់រៀបចំឃ្លាំង នឹងមានការលំបាក បើពុំបានគិតគូរជាមុន ។ ស្តង់ដានេះ ពិពណ៌នាពីតម្រូវការជាអប្បបរមានៃការរៀបចំឃ្លាំង សម្រាប់ប្រមូលផ្តុំ ក៏ដូចជាការរៀបចំប្រតិបត្តិការនៅការដ្ឋាន ។

ការរៀបចំឃ្លាំងជាមជ្ឈការ និងឃ្លាំងសម្រាប់ប្រតិបត្តិការនៅការដ្ឋាន គឺជាផ្នែកមួយដែលតម្រូវឲ្យអាជ្ញាធរមីនធ្វើអធិការកិច្ច ។

***

# ការរក្សាទុក ការដឹកជញ្ជូន និង ការប្រើប្រាស់រំសេវផ្ទុះ

## ១.ទំហំវិសាលភាព

ស្តង់ដានេះផ្តល់នូវសេចក្តីបញ្ជាក់យ៉ាងច្បាស់លាស់ និងគោលការណ៍ណែនាំសម្រាប់ការរក្សាទុក ដឹកជញ្ជូន និងប្រើប្រាស់រំសេវផ្ទុះប្រកបដោយសុវត្ថិភាព ដែលត្រូវអនុវត្តដោយប្រតិបត្តិករដោះមីន នៅក្នុងប្រទេសកម្ពុជា ។

នៅក្នុងស្តង់ដានេះ ពាក្យថា " **រំសេវផ្ទុះ** " គឺសំដៅលើរំសេវផ្ទុះ និងសម្ភារៈគ្រឿងផ្ទុះ វៀរលែងតែមានការបកស្រាយផ្សេងពីនេះនៅក្នុងអត្ថបទ ។

ស្តង់ដានេះមិនទាក់ទងទៅនឹងគ្រាប់ទម្លាក់ពីយន្តហោះ រ៉ុកកែត ឈ្នួនគ្រាប់ យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ឬ ប្រភេទគ្រាប់ដែលពោរពេញ ទៅដោយរំសេវផ្ទុះផ្សេងៗទៀតឡើយ ។

## ២.វាក្យស័ព្ទ និង និយមន័យ

សទ្ទានុក្រមនៃវាក្យស័ព្ទ និងនិយមន័យដែលបានប្រើប្រាស់នៅក្នុងស្តង់ដានេះ នឹងត្រូវបានរៀបចំចងក្រងក្នុងស្តង់ដាជាតិ នៅពេលខាងមុខ ។

ពាក្យថា "**រំសេវផ្ទុះ**" គឺសំដៅទៅលើសារជាតុ ឬ ល្បាយសារជាតុដែលឥទ្ធិពលខាងក្រៅរបស់វា អាចបញ្ចេញថាមពលយ៉ាងរហ័សទៅជាឧស្ម័ន និងកំដៅ ។

ពាក្យថា "**សម្ភារៈគ្រឿងផ្ទុះ**" គឺសំដៅទៅលើសមាសភាគ ឬ របស់បន្ទាប់បន្សំដែលមានរំសេវផ្ទុះ ដូចជាគីបផ្ទុះ ឈ្នួនផ្ទុះ និងគីបភ្នែកមាន់ ដែលប្រើប្រាស់ដោយប្រតិបត្តិករដោះមីន ។

## ៣.តម្រូវការទូទៅ

រំសេវផ្ទុះទំនើបៗ មានសុវត្ថិភាពក្នុងការរក្សាទុក ដឹកជញ្ជូន និងប្រើប្រាស់ បើប្រតិបត្តិការដោយអនុលោមទៅតាមការណែនាំរបស់ផលិតករ ។ ប្រតិបត្តិករដោះមីន មិនត្រូវប្រើប្រាស់រំសេវផ្ទុះដែលមានប្រភពមិនច្បាស់លាស់ ផុតកាលកំណត់ឡើយ ឬ ពេលរៀបចំឃ្លាំង លក្ខខ័ណ្ឌបរិយាកាសមិនត្រូវទៅតាមតម្រូវការរបស់ផលិតករ ។ អាជ្ញាធរមីន ឬ ប្រតិបត្តិករដោះមីន អាចបន្ថែមនូវតម្រូវការ ដោយផ្អែកលើបទពិសោធន៍ និងលក្ខខ័ណ្ឌនៅនឹងកន្លែងប្រើប្រាស់ ។

## ៤.តម្រូវការបរិស្ថាន

តម្រូវការបរិយាកាសជុំវិញ (សីតុណ្ហភាព សំណើម និង រំញ័រ) សម្រាប់រំសេវផ្ទុះផ្សេងៗ គឺអាស្រ័យលើស្ថានភាពនៃការរក្សាទុក ការដឹកជញ្ជូន និងការប្រើប្រាស់ ។ ការផ្ទុះនៃរំសេវ មិនអាចទាយទុកមុនបានឡើយ ហើយសុវត្ថិភាពត្រូវបានកាត់បន្ថយ បើមិនបំពេញបាននូវលក្ខខ័ណ្ឌបរិយាកាស ទៅតាមការណែនាំរបស់ផលិតករ ។ ជាទូទៅរំសេវផ្ទុះត្រូវ ៖

ក)-រក្សាទុកនៅកន្លែងស្ងួតល្អ និងមានខ្យល់ចេញចូល

ខ)-រក្សាទុកនៅកន្លែងដែលមានសីតុណ្ហភាពត្រជាក់ និងទុកឆ្ងាយពីគ្រឿងផ្ទុះដទៃទៀត ឬសីតុណ្ហភាពមិនប្រែប្រួល

គ)-ការពារកុំឲ្យត្រូវកំដៅថ្ងៃ

ឃ)-រក្សាទុកនៅន្លែងដែលពុំមានគ្រឿងផ្ទុះផ្សេងទៀត ឬ ការរង្គើជាញឹកញាប់ ។

**កំណត់ចំណាំ ៖**

១.សារធាតុមួយចំនួនដែលគេប្រើនៅក្នុងគ្រាប់រំសេវ រំសេវផ្ទុះ មានលក្ខណៈអាចស្រូបសំណើម ដែលជាហេតុបណ្តាលឲ្យរំសេវផ្ទុះថយឥទ្ធិពលរបស់វា ។ វាក៏អាចបណ្តាលឲ្យមានគ្រោះថ្នាក់ផងដែរ នៅពេលដែលយើងប្រើរំសេវផ្ទុះទាំងនោះ ដោយសារអានុភាពនៃភាពរវាសរបស់រំសេវផ្ទុះ។ ភ្លៀង សំណើម និង សន្សើម អាចបណ្តាលឲ្យខូចខាតយ៉ាងដំណំចំពោះរំសេវផ្ទុះនៅក្នុងរយៈពេលដ៏ខ្លី ។ ដូច្នេះ ត្រូវធ្វើយ៉ាងណាធានាឲ្យបានលក្ខខ័ណ្ឌស្ងួតក្នុងការរក្សាទុក និងការដឹកជញ្ជូន។

២.ការរក្សាទុករំសេវផ្ទុះ ដែលមានខ្យល់ចេញចូលល្អ នឹងអាចជួយរក្សាសីតុណ្ហភាពឲ្យនៅត្រជាក់ និងការពារកំណកញើសបាន ។

៣.សម្ភារៈនានាដែលមិនមែនជាគ្រឿងផ្ទុះ ដូចជាក្រណាត់ ហ្វីត ក្រដាស និងសម្ភារៈផ្សេងៗទៀត ដែលអាចស្រូបទឹកបាន នឹងក្លាយជាមូលហេតុ ដែលនាំឲ្យច្រេះស៊ី ពុក ផុយ និងខូចសម្ភារៈដទៃទៀត នៅក្នុងកុងទឺន័រតែមួយ ។

## ៥.តម្រូវការនៃការរក្សាទុក

### ៥.១.ការរៀបចំឃ្លាំង

តម្រូវការទូទៅសម្រាប់ការរៀបចំឃ្លាំង និងកុងទឺន័រ ដែលប្រើប្រាស់សម្រាប់ទុកដាក់ ដឹកជញ្ជូនរំសេវផ្ទុះ ប្រើនៅក្នុងដំណើរការដោះមីន មានចែងនៅក្នុងឧបសម្ព័ន្ធ ក ។

### ៥.២.សញ្ញាហាមឃាត់ និង រូបសំគាល់

កន្លែងដែលទុកដាក់រំសេវផ្ទុះ ត្រូវដាក់សញ្ញាសម្គាល់ឲ្យបានច្បាស់លាស់បំផុត។ ផ្លាកសញ្ញាត្រូវដាក់ឲ្យលេចធ្លោ ដើម្បីងាយមើលឃើញ អាចជាអក្សរខ្មែរ និងអង់គ្លេស។

### ៥.៣.វិធានការបង្ការអគ្គីភ័យ

ប្រតិបត្តិករដោះមីន ត្រូវបង្កើត និងថែទាំគោលការណ៍ នៃច្បាប់ការពារកុំឲ្យមានការឆាបឆេះភ្លើង និងបទដ្ឋានប្រតិបត្តិការ ដោយផ្អែកទៅលើគោលការណ៍រួម ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ខ ។

### ៥.៤.តារាងចម្ងាយសុវត្ថិភាព

ប្រតិបត្តិករដោះមីនទាំងអស់ ត្រូវអនុវត្តចម្ងាយសុវត្ថិភាព សម្រាប់ការរក្សាទុករំសេវផ្ទុះ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ គ លើកលែងតែមានការណែនាំផ្សេងពីនេះ ដោយអាជ្ញាធរមីន។

### ៥.៥.ការរៀបចំបន្ទប់ក្នុងឃ្លាំង

ការរៀបចំឃ្លាំងរំសេវផ្ទុះ មិនអនុញ្ញាតឲ្យធ្វើនៅក្នុងលំនៅដ្ឋាន កន្លែងស្នាក់នៅ ឬ ក្នុងអគារការិយាល័យឡើយ ។

## ៦.តម្រូវការផ្នែកដឹកជញ្ជូន

### ៦.១.ទូទៅ

ប្រតិបត្តិករដោះមីន ត្រូវបង្កើត និងថែទាំបទដ្ឋានប្រតិបត្តិការ ដែលផ្តល់បទដ្ឋានសុវត្ថិភាពក្នុងការដឹកជញ្ជូនរំសេវផ្ទុះ ។ បទដ្ឋាននេះ ត្រូវដាក់បញ្ចូលតម្រូវការដូចខាងក្រោមៈ

ក )-ធានាពីសន្តិសុខនៃរំសេវផ្ទុះ

ខ )-ដឹកជញ្ជូនរំសេវផ្ទុះ ដោយអនុលោមទៅតាមការណែនាំ និងសេចក្តីបញ្ជាក់របស់ផលិតករ

គ )-ដាក់សញ្ញាសម្គាល់រថយន្ត ដើម្បីបង្ហាញឲ្យដឹងពីការដឹកជញ្ជូនសម្ភារៈដែលមានគ្រោះថ្នាក់

ឃ )-ការការពារគ្រោះថ្នាក់ដោយអគ្គីភ័យ

ង )-ការពារកុំឲ្យមានគ្រោះថ្នាក់ ។

### ៦.២.អ្នកធ្វើដំណើរ

ប្រតិបត្តិករដោះមីន មិនត្រូវដឹកអ្នកដំណើរជាមួយរំសេវផ្ទុះឡើយ តែបើចាំបាច់ខានមិនបាន ត្រូវដឹកជាមួយរថយន្តដឹករំសេវផ្ទុះនោះ ត្រូវចាត់តាំងសមាជិកជាន់ខ្ពស់ក្រុមម្នាក់ឲ្យទទួលខុសត្រូវ ដោយត្រូវធានា សុវត្ថិភាពអ្នកដំណើរ និងចាត់វិធានការការពារគ្រោះអគ្គីភ័យ ។

### ៦.៣.ការដឹកជញ្ជូនគីប និង រំសេវផ្ទុះ

មិនត្រូវដឹកគីប និងរំសេវផ្ទុះ នៅក្នុងរថយន្តជាមួយគ្នាទេ លើកលែងតែកុងទីន័រដែលផ្ទុកគីបនោះមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមតម្រូវការ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ ក ។

### ៦.៤.ឧបករណ៍ពិសេស

ប្រដាប់ពន្លត់ភ្លើង ចំណុះ៩លីត្រចំនួនមួយ ឬ ប្រហាក់ប្រហែល និងកុងទីន័រមួយ សម្រាប់ផ្ទុកសម្ភារៈមានផ្សេង ដូចជាឈើគូស ដែកកេស បារី ។ល។ ត្រូវផ្ទុកជាមួយរថយន្តទាំងអស់ ដែលដឹកគ្រឿងផ្ទុះ។

## ៧.ការប្រើប្រាស់

ប្រតិបត្តិករដោះមីនទាំងអស់ត្រូវបង្កើត និងរក្សាទុកបទដ្ឋានប្រតិបត្តិការ ដែលផ្តល់នីតិវិធីប្រកបដោយសុវត្ថិភាព ក្នុងការប្រើប្រាស់រំសេវផ្ទុះ ។ នីតិវិធីទាំងនោះ ត្រូវដាក់បញ្ចូលនូវតម្រូវការដូចខាងក្រោមៈ

ក)-ត្រូវត្រួតពិនិត្យឲ្យបានតឹងរឹង នូវការចេញចូលទៅកន្លែងទុកដាក់រំសេវផ្ទុះ ។

ខ)-ត្រូវប្រើប្រាស់រំសេវផ្ទុះ ឲ្យស្របទៅតាមសេចក្តីណែនាំ និងសេចក្តីបញ្ជាក់របស់ផលិតករ។

គ)-មានតែបុគ្គលិកដោះមីន ដែលមានលក្ខណសម្បត្តិត្រឹមត្រូវ ឬ បុគ្គលិកដែលគ្រប់គ្រងដោយអ្នកត្រួតពិនិត្យ ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់តែប៉ុណ្ណោះ ដែលអាចប្រើប្រាស់រំសេវផ្ទុះបាន។

## ៨.គ្រាប់និចល គ្រាប់សម្រាប់ហ្វឹកហាត់ ឬគ្រាប់មីន និងរំសេវសិប្បនិម្មិត

គ្រាប់មីន និងគ្រាប់រំសេវ មានគ្រោះថ្នាក់ខ្លាំងជាទីបំផុត ដូច្នេះអ្នកដែលពាក់ព័ន្ធក្នុងការប្រើប្រាស់ និងការដឹកជញ្ជូនគ្រាប់រំសេវ ត្រូវប្រុងប្រយ័ត្នកំរិតខ្ពស់ ។ ជាការពិតណាស់ដែលថា ការប្រើប្រាស់គ្រាប់មីន និងគ្រាប់រំសេវដែលបានបន្សាប (ធ្វើឲ្យលែងផ្ទុះ) សម្រាប់ហ្វឹកហ្វឺនវាមានសុវត្ថិភាពជាង តែក៏មានតម្រូវការដាក់លាក់ផ្ទាល់ សម្រាប់បញ្ចៀសគ្រោះថ្នាក់ដែរ ។ ដូច្នេះ ជាគោលការណ៍មូលដ្ឋាននៃសុវត្ថិភាពគ្រាប់រំសេវ និង រំសេវផ្ទុះ មិនត្រូវដាក់លាយឡំជាមួយរំសេវផ្ទុះ ដែលបានបន្សាបរួច ឬគ្រាប់ចម្លងសម្រាប់ហ្វឹកហ្វឺនឡើយ។ នេះគឺជាគោលការណ៍មួយ ក្នុងការកាត់បន្ថយគ្រោះថ្នាក់ នៅពេលហ្វឹកហ្វឺន និងពេលហាត់រៀនឲ្យដល់កម្រិតអប្បបរមា។ ផលវិបាកនៃការយកគ្រាប់មីន និងគ្រាប់រំសេវដែលមានសុពលភាព ទៅប្រើប្រាស់សម្រាប់ហ្វឹកហ្វឺន អាចបណ្តាលឲ្យស្លាប់ ឬ របួស បើសិនជាមានការធ្វេសប្រហែស ។

ប្រតិបត្តិករដោះមីន ត្រូវបង្កើត និងថែទាំបទដ្ឋានប្រតិបត្តិការ សម្រាប់ការរៀបចំទុកដាក់ ការប្រើប្រាស់គ្រាប់មីន និងគ្រាប់រំសេវដែលបានបន្សាបរួច ឬ ការចម្លងគ្រាប់សម្រាប់ហ្វឹកហ្វឺន ដោយដាក់បញ្ចូល តម្រូវការនានាដែលមាននៅក្នុងឧបសម្ព័ន្ធ ឃ ។

## ៩.សន្តិសុខ

ប្រតិបត្តិករដោះមីនទាំងអស់ ត្រូវផ្តោតការយកចិត្តទុកដាក់កំរិតខ្ពស់ លើសន្តិសុខនៃការកាន់កាប់ គីប និងរំសេវផ្ទុះទាំងអស់ នៅពេលរក្សាទុកក្នុងឃ្លាំង ការដឹកជញ្ជូន និងការប្រើប្រាស់។ គេក៏ត្រូវយកចិត្តទុកដាក់ មិនគ្រាន់តែលើសន្តិសុខផ្ទាល់នៃគីប និងរំសេវផ្ទុះប៉ុណ្ណោះទេ ប៉ុន្តែត្រូវគ្រប់គ្រងអោយបានហ្មត់ចត់ នូវចំនួនចេញ-ចូលផងដែរ។

## ១០.ភារៈទទួលខុសត្រូវ និង ភារកិច្ច

### ១០.១.អាជ្ញាធរមីន

អាជ្ញាធរមីន ត្រូវរៀបចំឯកសារបទដ្ឋាន សម្រាប់ត្រួតពិនិត្យការរៀបចំឃ្លាំង ការដឹកជញ្ជូន និងការប្រើប្រាស់រំសេវផ្ទុះ ដោយរាប់បញ្ចូលទាំងៈ

ក)-ការត្រួតពិនិត្យការរៀបចំឃ្លាំងរំសេវផ្ទុះ រាប់បញ្ចូលទាំងការរៀបចំឃ្លាំងនៅការដ្ឋានដោះមីន

ខ)-ការត្រួតពិនិត្យការដឹកជញ្ជូនរំសេវផ្ទុះ រាប់បញ្ចូលទាំងផ្លាកសញ្ញាព្រមាន និងរូបសញ្ញាដែលប្រើប្រាស់នៅលើរថយន្ត

គ)-ការត្រួតពិនិត្យ ចម្ងាយសុវត្ថិភាពសម្រាប់ការរៀបចំឃ្លាំង និងការប្រើប្រាស់វត្ថុផ្ទុះ ។

**១០.២.ប្រតិបត្តិករដោះមីន**

ប្រតិបត្តិករដោះមីន ត្រូវបង្កើត និងថែទាំបទដ្ឋានប្រតិបត្តិការ ឲ្យស្របទៅនឹងបញ្ញត្តិទាំងឡាយដែលមានចែងក្នុងស្តង់ដានេះ ។

**១០.៣.អ្នកដោះមីន**

អ្នកដោះមីនត្រូវៈ

ក)-អនុវត្តទៅតាមការណែនាំរបស់ប្រតិបត្តិករដោះមីន លើសុវត្ថិភាពនៅពេលរៀបចំឃ្លាំង ការដឹកជញ្ជូន និង ការប្រើប្រាស់វត្ថុផ្ទុះ

ខ)-រាយការណ៍ជូនអ្នកដឹកនាំជាបន្ទាន់ នូវស្ថានការណ៍ណាដែលពាក់ព័ន្ធនឹងការរៀបចំឃ្លាំង ការដឹកជញ្ជូន និងការប្រើប្រាស់វត្ថុផ្ទុះ ដែលជឿជាក់ថា នឹងអាចមានគ្រោះថ្នាក់កើតឡើង ហើយខ្លួនមិនអាចកែតម្រូវបាន ។

រាជធានីភ្នំពេញ ថ្ងៃទី 20 ខែ ៣ ឆ្នាំ ២០០៥

**អគ្គលេខាធិការ**

**សម សុគ្គា**

## ឧបសម្ព័ន្ធ ក

## តម្រូវការទូទៅសម្រាប់សាងសង់ឃ្លាំង

### ១.សំណង់អចិន្ត្រៃយ៍

សំណង់ឃ្លាំងអចិន្ត្រៃយ៍ អាចជាអគារ រូងក្នុងដី ឬ ល្អាង ដោយមិនអាចឆេះ ចោរលួចមិនបាន សុាំទៅនឹងអាកាសធាតុ មានខ្យល់ចេញចូលគ្រប់គ្រាន់ និងត្រូវពិចារណាអំពីស្ថានភាពដី លក្ខណៈភូមិសាស្ត្រក្នុងមូលដ្ឋានក្នុងពេលធ្វើគម្រោង និងចាប់ផ្តើមសាងសង់ ។

ការចាក់គ្រឹះ និងចាក់កំរាលបេតុង ការប្រើថ្ម ឬ ឥដ្ឋ ត្រូវធ្វើទៅតាមគម្រោងនៃការសាងសង់ ដោយស្របទៅតាមអគារស្តង់ដាជាតិ។ បើសិនជាគេប្រើសំណង់ ឬ បង្គោលដែលលយចេញ កន្លែងដែលចំពីក្រោមអគារនោះត្រូវប្រើបេតុងជាមួយដែក។

ជញ្ជាំង ត្រូវសង់ពីដែកថែប ឈើ បាយអ ឬ សម្ភារៈមួយចំនួនទៀតដែលភ្លើងមិនអាចឆេះ និងមានលក្ខណៈជាសំណង់មាំល្អ ។

**កំណត់ចំណាំ:**

១.ឈើសំណង់អគារផ្នែកខាងក្រៅ ត្រូវស្រោបដោយសម្ភារៈដែលភ្លើងមិនឆេះ (បើអាចធ្វើទៅបានគួរជៀសវាងការប្រើប្រាស់ឈើ ពីព្រោះវាងាយឆេះ) ។

២.ចន្លោះបេតុង ឥដ្ឋ គួរចាក់បំពេញដោយដីខ្សាច់បង្ហាប់ឲ្យណែនល្អ ឬ ចាក់បំពេញខ្សាច់លាយជាមួយស៊ីម៉ង់ត៍ ។

៣.ជញ្ជាំងខាងក្នុង គួរស្រោបដោយឈើ ឬ សម្ភារៈមួយចំនួនទៀតដែលមិនមានផ្កាភ្លើង។

កម្រាល គួរជាបេតុងយ៉ាងវិសេស ក្រាលពីលើឲ្យបានសមរម្យ ដោយសម្ភារៈដែលមិនមានផ្កាភ្លើង។

ដំបូល ត្រូវសង់ពីសម្ភារៈសំណង់ដែលមាំទាំ ភ្លើងមិនឆេះ ហើយសុាំនឹងអាកាសធាតុ។ ដំបូល ឬ ពិដានគួរដាក់ប្រដាប់ការពារកំដៅ ដើម្បីជួយរក្សាសីតុណ្ហភាពខាងក្នុងឲ្យនៅក្រោម ៤០អង្សាសេ។ ទ្វារ ត្រូវធ្វើឲ្យបានរឹងមាំ ត្រចៀកទ្វារ និងរីសសម្រាប់ចាក់សោរត្រូវផ្សារមិណ ឬ ចាប់ប៊ូឡុងឲ្យជាប់ ដើម្បីកុំឲ្យគេដោះបាន នៅពេលចាក់សោរទ្វារ។ ទ្វារ គួរធ្វើបើកចេញមកខាងក្រៅ។ ត្រូវរៀបចំឲ្យមានផ្លូវខ្យល់ចេញចូលគ្រប់គ្រាន់ ដើម្បីការពារញើស សើម និង កំដៅ ដល់វំសេវផ្ទុះដែលផ្ទុកក្នុងឃ្លាំង។ លក្ខខ័ណ្ឌអាកាសធាតុ ទំហំឃ្លាំង និងទីតាំងនឹងត្រូវកំណត់ ទៅតាមតម្រូវការនៃបរិមាណខ្យល់ចេញចូល។ ការដ្ឋានត្រូវមានចង្អូរបង្ហូរទឹកគ្រប់គ្រាន់ ដើម្បីបង្ការការខូចខាតដោយសារទឹក ចំពោះសម្ភារៈដែលមាននៅក្នុងឃ្លាំងទាំងអស់។ ត្រូវប្រើសោរល្អមាំ ដើម្បីចាក់សោរទ្វារឃ្លាំង ។

## ២.ឃ្លាំងចល័ត ឬ ឃ្លាំងដែលអាចដឹកជញ្ជូនបាន

ឃ្លាំងដែលអាចចល័តបាន គឺជាសំណង់ដែលអាចដឹកជញ្ជូនបាន ដូចជាកុងទឺន័រ រថសណ្តោង ឬ រថសណ្តោងធុនតូច។

ឃ្លាំងដែលអាចដឹកជញ្ជូនបាន ឬ ឃ្លាំងចល័ត ត្រូវធន់នឹងភ្លើង ធន់នឹងអាកាសធាតុ និង ចោរមិនអាចលួចបាន។ ឃ្លាំងនេះ គួរសាងសង់ពីដែកដោយប្រើឈើទ្រាប់ខាងក្នុង។

ឃ្លាំងនេះ គួរមានទម្រ ដើម្បីជៀសវាងការដាក់ផ្ទាល់នៅលើដី ឃ្លាំងទាំងឡាយណាដែលមានទំហំតូចជាងមួយម៉ែត្រគូប គួរដាក់ភ្ជាប់ទៅនឹងវត្ថុអចល័ត ដើម្បីការពារចោរលួចឃ្លាំងទាំងមូល។

ទ្វារ ត្រូវធ្វើឲ្យបានមាំទាំ ត្រចៀកទ្វារ និងវីសសម្រាប់ចាក់សោរ ត្រូវផ្សារមិណ ឬ ចាប់ប៊ូឡុងឲ្យជាប់ល្អ ដើម្បីកុំឲ្យគេបើកបាន នៅពេលចាក់សោរទ្វារ។

ត្រូវរៀបចំឲ្យមានផ្លូវខ្យល់ចេញចូលគ្រប់គ្រាន់ ដើម្បីការពារញើស សើម និងកំដៅ ដល់វំសេវផ្ទុះ ដែលផ្ទុកក្នុងឃ្លាំង។

លក្ខខ័ណ្ឌអាកាសធាតុ ទំហំឃ្លាំង និងទីតាំង នឹងត្រូវកំណត់ទៅតាមតម្រូវការនៃបរិមាណខ្យល់ចេញចូល។

## ៣.ប្រអប់ប្រចាំថ្ងៃ

ប្រអប់ផ្ទុករំសេវប្រចាំថ្ងៃ ត្រូវរៀបចំចាក់សោរអោយបានជាប់លាប់។

ឃ្លាំងនេះ ត្រូវមានសៀវភៅកត់ត្រាចំនួនរំសេវចេញ-ចូលច្បាស់លាស់ និងត្រូវផ្ទេរទៅទុកនៅឃ្លាំង ដែលអាចដឹកបាន ឃ្លាំងចល័ត ឃ្លាំងអចិន្ត្រៃយ៍។

## ៤.ការដឹកជញ្ជូនកុងទឺន័រសម្រាប់ផ្ទុកគីប

គីប និងរំសេវផ្ទុះផ្សេងទៀត អាចដឹកជាមួយគ្នាលើរថយន្តតែមួយ ដោយប្រើកុងទឺន័រសម្រាប់ ដឹកគីប ឬ បន្ទប់ដែលគេគ្រោងនឹងសង់ឡើងយ៉ាងជាក់លាក់សម្រាប់ដឹកជញ្ជូន។ នៅពេលដឹកជញ្ជូនគីប និងរំសេវផ្ទុះផ្សេងទៀតនៅលើរថយន្តតែមួយ កុងទឺន័រផ្ទុកគីប ត្រូវដាក់ដាច់ដោយឡែកពីរំសេវផ្ទុះ ឬ គីប ត្រូវផ្ទុកនៅក្នុងកាប៊ីនរថយន្ត ។

ការប្រើប្រាស់កុងទឺន័រសម្រាប់ផ្ទុកគីបត្រូវអនុវត្តលក្ខខ័ណ្ឌដូចខាងក្រោមៈ

ក )-ហាមផ្ទុកសម្ភារៈពីលើកុងទឺន័រផ្ទុកគីប

ខ )-កុងទឺន័រផ្ទុកគីប ត្រូវរៀបឲ្យស្រួល ឬ ចងឲ្យជាប់ ដើម្បីការពារកុំឲ្យមានចលនានៅពេលដឹកជញ្ជូន

គ )-កុងទឺន័រនេះត្រូវបិទអក្សរជាភាសាខ្មែរ និងអង់គ្លេសថា "*កុងទឺន័រផ្ទុកគ្រឿងផ្ទុះ សូមលើកដាក់ ដោយប្រុងប្រយ័ត្ន*"។

## ៥.ការរៀបចំឃ្លាំងនៅការដ្ឋានដោះមីន

វំសេវផ្ទុះ មីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងសម្ភារៈដែលមានគ្រោះថ្នាក់ទាំងអស់ អាចរក្សាទុកនៅ ការដ្ឋានដោះមីន។ វំសេវផ្ទុះដែលប្រើនៅក្នុងដំណើរការដោះមីន គួររក្សាទុកនៅក្នុងកុងទឺន័រ ដែលបានអនុម័តឲ្យផ្ទុកទៅតាមប្រភេទ និងចំនួនវំសេវផ្ទុះ ហើយត្រូវមានទីតាំងនៅកន្លែងដែលមានសុវត្ថិភាពនៃការដ្ឋានដោះមីន។

នៅពេលដែលស្តង់ដានេះមិនឆ្លើយតបទៅនឹងការរក្សាទុកនៅក្នុងកុងទឺន័រ ប្រតិបត្តិករដោះមីន ត្រូវទទួលខុសត្រូវក្នុងការផ្តល់វិធានការសុវត្ថិភាពឲ្យបានគ្រប់គ្រាន់ (កិច្ចការការពារ ចម្ងាយសុវត្ថិភាព របង សន្តិសុខ។ល។) និងត្រូវដាក់បញ្ចូលផងដែរនូវការការពារទល់នឹងកត្តាបរិស្ថាន ដោយអនុលោមតាមសេចក្តីណែនាំរបស់ផលិតករ ។ ការរក្សាទុកបែបនេះ គឺជាវិធានការបណ្តោះអាសន្នតែប៉ុណ្ណោះ។

ឃ្លាំងរបស់ការដ្ឋានដោះមីន គឺជាទម្រង់នៃការរៀបចំការដ្ឋានទាំងមូល។ តម្រូវការជាអប្បបរមា មានដូចខាងក្រោមនេះ ៖

ក)-វំសេវផ្ទុះ និងគីប ត្រូវទុកដាក់នៅកន្លែងដាច់ដោយឡែកពីគ្នានៅតាមការដ្ឋានដោះមីន ហើយទុកដាក់អោយផុតពីដីដោយការប្រើកំណល់ និងដាក់របាំងបាវខ្សាច់ពីរជួរ ដើម្បីការពារ ព្រមទាំងដំបូលការពារផង។

ខ)-រូងទាំងពីរនោះត្រូវមានគម្លាតមួយម៉ែត្រពីគ្នា។

គ)-គីបត្រូវទុកនៅក្នុងរូងមួយ ហើយវំសេវផ្ទុះ និងគ្រឿងផ្ទុះផ្សេងទៀត ត្រូវទុកនៅក្នុងរូងមួយផ្សេងទៀត។

ឃ)-ត្រូវសង់ដំបូលបណ្តោះអាសន្នមួយ (ប្រើឈើ ឬ សម្ភារៈមិនមែនលោហៈ) ប្រក់ពីលើរូង ដើម្បីការពារពីបរិយាកាសជុំវិញ និងដើម្បីកុំឲ្យទឹកហូរចូល។

ង)-នៅតំបន់ជុំវិញរូង ត្រូវដាក់សញ្ញាឲ្យបានច្បាស់ថាជាតំបន់មានគ្រឿងផ្ទុះ។

ច)-កន្លែងនោះត្រូវដាក់បាំាស់ ឬ របងសន្តិសុខនៅពេលដែលវំសេវផ្ទុះត្រូវបានរក្សាទុកនៅទីនោះ។

ឆ)-បើចាំបាច់ ត្រូវរក្សាទុកគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដើម្បីកំទេចនៅពេលក្រោយ។

ត្រូវសង់ឃ្លាំងដោយឡែកមួយទៀត ដោយអនុលោមតាមតម្រូវការដែលបានអត្ថាធិប្បាយខាងលើ ។

***

## ឧបសម្ព័ន្ធ ខ (ជាព័ត៌មាន)

## វិធានការបង្ការអគ្គីភ័យ

ប្រតិបត្តិករដោះមីន ដែលទទួលខុសត្រូវក្នុងការរក្សាទុករំសេវផ្ទុះ និងគ្រឿងផ្ទុះ ត្រូវបង្កើតគោលការណ៍ច្បាប់ និងនីតិវិធីប្រតិបត្តិការ សម្រាប់ការពារភ្លើងឆេះ ដោយដាក់បញ្ចូលនូវតម្រូវការចាំបាច់ មួយចំនួនដូចខាងក្រោមៈ

ក)-ហាមជក់បារី ក្នុងចម្ងាយ ២០ម ពីឃ្លាំង។ ផ្លាកសញ្ញា " **ហាមជក់បារី ហាមបញ្ឆេះភ្លើង** " ត្រូវដាក់ឲ្យងាយឃើញនៅជុំវិញឃ្លាំង។

ខ)-ស្មៅ និងកូនឈើតូចៗ ដែលដុះនៅជុំវិញឃ្លាំង ត្រូវកាត់ឲ្យខ្លី។

គ)-ភ្លើង និងសម្ភារៈដែលបង្កើតជាផ្កាភ្លើង មិនត្រូវឲ្យមាននៅក្នុងចម្ងាយ២០មពីឃ្លាំងឡើយ។ បើសម្ភារៈទាំងនេះ ត្រូវការចាំបាច់ដើម្បីធ្វើការជួសជុលឃ្លាំងនោះ រំសេវផ្ទុះទាំងអស់ ត្រូវដឹកជញ្ជូនចេញ។

ឃ)-ថ្នាំលាប ប្រេងរំអិល ប្រេងសាំង ឬ សម្ភារៈដែលងាយឆេះផ្សេងទៀត មិនត្រូវទុកជាមួយរំសេវផ្ទុះទេ។ សម្ភារៈសម្រាប់ជូតសម្អាតខ្លះអាចប្រើប្រាស់នៅក្នុងឃ្លាំងបានពេលថែទាំជូតសម្អាតសម្ភារៈ ប៉ុន្តែត្រូវយកចេញវិញនៅពេលឈប់ប្រើ ។

ង)-កុងទីន័រដែលអត់មានសម្ភារៈមិនត្រូវទុកនៅជាមួយរំសេវផ្ទុះឡើយ ។

ច)-ត្រូវមានបំពង់ពន្លត់ភ្លើងចំណុះ៩លីត្រ ចំនួនមួយយ៉ាងតិច ដាក់នៅខាងក្រៅឃ្លាំងរំសេវផ្ទុះ នៅកន្លែងដែលងាយមើលឃើញ ។

ឆ)-សម្ភារៈពន្លត់ភ្លើងទាំងអស់ ត្រូវថែទាំឲ្យមានលក្ខណៈល្អ ប្រើការបានមួយរយភាគរយ ។

ជ)-វិធីខ្លះៗ ដើម្បីការពាររន្ទះ គួរប្រើប្រាស់ ។

ឈ)-តារាងរាយឈ្មោះវត្ថុដែលមិនអនុញ្ញាតឲ្យយកចូលទៅក្នុងឃ្លាំង ត្រូវដាក់បង្ហាញនៅពីមុខក្លោងទ្វារចូលឃ្លាំង ។ វត្ថុទាំងនោះរួមមានៈ

-ចង្កៀងគោម ចង្កៀងប្រេង ចង្ក្រាន និងភ្លើង ឬ ប្រដាប់ប្រដារប្រើប្រាស់ដែលបង្កើតឲ្យមានភ្លើង

-ឈើគូស ប្រដាប់អុជបារី ឬ សម្ភារៈផ្សេងៗទៀត ដែលបង្កើតផ្កាភ្លើង និងភ្លើង

-ថ្នាំជក់ និងរបស់សម្រាប់ជក់គ្រប់ប្រភេទ

-វត្ថុរាវដែលងាយឆេះ និងវត្ថុបំលែងដទៃទៀត លើកលែងតែរបស់ដែលអនុញ្ញាតឲ្យយកចូលដើម្បីថែទាំ ជូតសម្អាតកុងទីន័រ ឬ ប្រេងដែលមាននៅក្នុងធុងប្រេងរថយន្ត

-អាហារ និងភេសជ្ជៈ

-ឧបករណ៍វិទ្យុទាក់ទង (គ្រប់ប្រភេទ) រួមទាំងទូរស័ព្ទចល័ត

-ឱសថ និងថ្នាំពេទ្យ លើកលែងតែថ្នាំដែលមាននៅក្នុងប្រអប់សង្គ្រោះបឋម

-គ្រាប់រំសេវដែលមិនអនុញ្ញាតឲ្យរក្សាទុក

-រាល់ប្រភពថាមពលដែលមិនមានឧបករណ៍ការពារ។

៣)-ការដាក់ផ្លាកសញ្ញានៅខាងក្រៅស្តីពីការរៀបចំឃ្លាំង ត្រូវរៀបរាប់លំអិតពីចំណុចដែលត្រូវទាក់ទង នៅពេលមានការចាំបាច់ និងធ្វើបញ្ជីសម្ភារៈដែលមានគ្រោះថ្នាក់។

ដ)-ការបង្កប់ខ្សែភ្លើងសម្រាប់តចរន្តអគ្គីសនី ត្រូវចងរុំខ្សែភ្លើងទាំងអស់ និងកប់ឲ្យបានល្អ។

ឋ)-សញ្ញាបន្លឺភ្លើងឆេះ ជាឧបករណ៍បន្លឺសម្លេងរោទ៍នៅពេលដែលមានភ្លើងឆេះ។

ឌ)-រូបសញ្ញាភ្លើង ត្រូវដាក់បង្ហាញនៅខាងក្រៅអគារនីមួយៗ ដែលមានផ្ទុកគ្រាប់រំសេវ ដើម្បីជាសញ្ញាឲ្យបុគ្គលិកប្រុងប្រយ័ត្នចំពោះគ្រោះថ្នាក់ ដែលពាក់ព័ន្ធជាមួយគ្រាប់រំសេវ នៅពេលមានភ្លើងឆេះ ។

***

## ឧបសម្ព័ន្ធ គ (ជាព័ត៌មាន)

## តារាងចម្ងាយសុវត្ថិភាពសម្រាប់រៀបចំឃ្លាំងគ្រឿងផ្ទុះ

| ចំនួនរំសេវផ្ទុះ គិតជាគីឡូក្រាម | | ចម្ងាយគិតជា ម៉ែត្រ | | | | | |
|---|---|---|---|---|---|---|---|
| | | អគារដែលមានមនុស្ស រស់នៅ ចម្ងាយគិតជាម៉ែត្រ | | ផ្លូវសាធារណៈ | | ការខ័ណ្ឌបំបែកឃ្លាំង | |
| លើសពី | តិចជាង | មានរបាំង | អត់របាំង | មានរបាំង | អត់របាំង | មានរបាំង | អត់របាំង |
| 0 | 2 | 32 | 64 | 14 | 27 | 3 | 5 |
| 2 | 5 | 41 | 82 | 16 | 32 | 4 | 7 |
| 5 | 9 | 50 | 100 | 20 | 41 | 5 | 9 |
| 9 | 14 | 57 | 114 | 23 | 45 | 5 | 10 |
| 14 | 18 | 64 | 127 | 25 | 50 | 5 | 11 |
| 18 | 23 | 68 | 136 | 27 | 54 | 6 | 13 |
| 23 | 34 | 77 | 154 | 32 | 64 | 7 | 14 |
| 34 | 45 | 86 | 173 | 34 | 68 | 7 | 15 |
| 45 | 57 | 91 | 182 | 36 | 73 | 8 | 16 |
| 57 | 68 | 98 | 195 | 39 | 77 | 9 | 17 |
| 68 | 91 | 107 | 213 | 43 | 86 | 10 | 19 |
| 91 | 114 | 116 | 232 | 48 | 95 | 10 | 21 |
| 114 | 136 | 123 | 245 | 50 | 100 | 11 | 22 |
| 136 | 182 | 134 | 268 | 54 | 109 | 12 | 25 |
| 182 | 227 | 145 | 291 | 59 | 118 | 13 | 26 |
| 227 | 272 | 109 | 218 | 61 | 123 | 14 | 28 |
| 272 | 318 | 161 | 322 | 66 | 132 | 15 | 29 |
| 318 | 363 | 170 | 341 | 68 | 136 | 15 | 30 |
| 363 | 409 | 177 | 354 | 70 | 141 | 16 | 32 |
| 409 | 454 | 182 | 363 | 73 | 145 | 16 | 33 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 454 | 545 | 193 | 386 | 75 | 150 | 18 | 35 |
| 545 | 636 | 204 | 409 | 77 | 154 | 19 | 37 |
| 636 | 726 | 213 | 427 | 79 | 159 | 20 | 39 |
| 726 | 817 | 222 | 445 | 82 | 163 | 20 | 40 |
| 817 | 908 | 229 | 459 | 84 | 168 | 20 | 41 |
| 908 | 1135 | 247 | 495 | 86 | 173 | 22 | 44 |
| 1135 | 1362 | 263 | 527 | 89 | 177 | 24 | 47 |
| 1362 | 1816 | 288 | 577 | 95 | 191 | 26 | 53 |
| 1816 | 2270 | 311 | 622 | 102 | 204 | 28 | 55 |
| 2270 | 2724 | 331 | 663 | 107 | 213 | 30 | 59 |

**កំណត់ចំណាំ:**

១-ការដាក់របាំង គឺមានបំណងបាំងឃ្លាំងដែលមានរំសេវផ្ទុះ ពីអគារដែលមានរំសេវផ្ទុះ អគារផ្សេងៗទៀត ផ្លូវរថភ្លើង ឬ ផ្លូវថ្នល់ ដោយប្រើប្រាស់របាំងធម្មជាតិ ឬ សិប្បនិម្មិត ខ្សែបន្ទាត់ត្រង់ពីកំពូលជញ្ជាំងអគារ ឬ ឃ្លាំងដែលផ្ទុករំសេវផ្ទុះ ទៅកាន់ចំណុចដែលលយចេញរបស់អគារផ្សេងទៀត ដែលមានប្រវែង៣.៥ម៉ែត្រ ពីលើខ្សែបន្ទាត់កណ្តាល នៃផ្លូវថ្នល់ ឬផ្លូវរថភ្លើងត្រូវឆ្លងកាត់របាំងនេះ។

២-របាំងសិប្បនិម្មិតគឺជាការលើកដី ឬទប់ដី ធ្វើជាជញ្ជាំងដែលមានកម្រាស់មិនតិចជាង ៩០ សង្ទីម៉ែត្រ ។

៣-របាំងធម្មជាតិ គឺជាលក្ខណៈធម្មជាតិពិតៗ នៃភូមិសាស្ត្រ ដូចជាកូនភ្នំ ដើមឈើច្រើនដែលអាចបាំងរវាងឃ្លាំង និង អគារ ឬ ជាលក្ខណៈដែលត្រូវការពារនៅពេលដើមឈើទាំងនោះជ្រុះស្លឹកអស់ ។

៤-ការរក្សាទុករំសេវផ្ទុះដែលមានចំនួនលើសពី ២៧២៤ គ.ក ត្រូវរៀបចំឃ្លាំងទុកដាក់ជាអចិន្ត្រៃយ៍ នេះជាច្បាប់ដែលបានកំណត់ដោយអាជ្ញាធរមីន ។

***

## ឧបសម្ព័ន្ធ ឃ (ធម្មតា)

## គ្រាប់និចល គ្រាប់សម្រាប់ហ្វឹកហាត់ ឬ គ្រាប់មីន និងរំសេវសិប្បនិម្មិត

### ១.ទូទៅ

គោលបំណងនៃឧបសម្ព័ន្ធនេះ គឺដើម្បីធានាថា គ្រាប់និចល គ្រាប់សម្រាប់ហ្វឹកហាត់ ឬ គ្រាប់មីន និងរំសេវសិប្បនិម្មិតត្រូវបានប្រើប្រាស់ រក្សាទុក និង ពិចារណាឲ្យបានត្រឹមត្រូវ ដើម្បីៈ

ក)-ជៀសវាងគ្រោះថ្នាក់។

ខ)-ជៀសវាងឧប្បត្តិហេតុនៃការកំណត់អត្តសញ្ញាណច្រឡំ ដែលបណ្តាលមកពីប្រតិបត្តិការដោះមីន មានការធ្វេសប្រហែស ឬ បទដ្ឋានធ្វើឲ្យមានសុវត្ថិភាព មិនត្រូវបានយកចិត្តទុកដាក់ ។

គ)-ធានាសន្តិសុខនៃគ្រាប់មីន និងគ្រាប់រំសេវនិចល។

ឃ)-ធានាថា នឹងមិនធ្វើឲ្យខូចខាតចំពោះគ្រាប់មីន និងគ្រាប់រំសេវនិចល ។

### ២.ការរក្សាទុក

គ្រាប់មីន និងគ្រាប់រំសេវនិចល ឬ គ្រាប់សិប្បនិម្មិតផ្សេងទៀត សម្រាប់ហាត់រៀន មិនត្រូវរក្សាទុកនៅក្នុងឃ្លាំងជាមួយគ្រាប់រំសេវពិតប្រាកដឡើយ ។ គ្រាប់និចលទាំងនោះ ត្រូវរក្សាទុកដោយឡែកនៅក្រៅ ឃ្លាំងរំសេវផ្ទុះ។

គ្រាប់មីន និងគ្រាប់រំសេវផ្ទុះដែលត្រូវបានធ្វើឲ្យមានសុវត្ថិភាព នឹងត្រូវបានបញ្ជាក់ថាពុំមានរំសេវផ្ទុះទៀតនោះ (FFE) ត្រូវរក្សាទុកនៅក្នុងលក្ខណៈជាគ្រាប់រំសេវនិចល និងសម្រាប់ហាត់រៀន។

គ្រាប់មីន គ្រាប់រំសេវនិចល ឬគ្រាប់សិប្បនិម្មិតសម្រាប់ហាត់រៀន មិនត្រូវរក្សាទុកនៅក្នុងកុងទីន័រ ជាមួយគ្រាប់រំសេវផ្ទុះពិតប្រាដកឡើយ ត្រូវរក្សាទុកនៅក្នុងកុងទីន័រដាច់ដោយឡែកពីគ្នា ហើយត្រូវដាក់ផ្លាកសញ្ញាឲ្យបានច្បាស់លាស់ជាភាសាខ្មែរ និងអង់គ្លេសថា "**គ្រាប់រំសេវនិចល ឬ គ្រាប់សម្រាប់ហាត់រៀន**" ។ ផ្លាកសញ្ញាដទៃទៀត ត្រូវយកចេញឲ្យអស់ពីកុងទីន័រ ដើម្បីកុំឲ្យច្រឡំថា ជាកុងទីន័ររំសេវផ្ទុះពិតប្រាកដ ។

### ៣.ចលនា

គ្រាប់មីន និងគ្រាប់រំសេវនិចល ឬគ្រាប់សិប្បនិម្មិតសម្រាប់ហាត់រៀន មិនត្រូវដឹកជញ្ជូនចូលកុងទីន័រ ជាមួយគ្រាប់រំសេវពិតប្រាកដឡើយ។ ត្រូវដឹកជញ្ជូនចូលកុងទីន័រដាច់ដោយឡែក ហើយត្រូវដាក់សញ្ញាឲ្យបានច្បាស់លាស់ជាភាសាខ្មែរ និងអង់គ្លេស ថាគ្រាប់រំសេវនិចល ឬ គ្រាប់សម្រាប់ហាត់រៀន ។ ផ្លាកសញ្ញាដទៃទៀត ត្រូវយកចេញឲ្យអស់ពីកុងទីន័រ ដើម្បីកុំឲ្យច្រឡំថាជាកុងទីន័ររំសេវផ្ទុះពិតប្រាកដ ។

ជាអនុសាសន៍ គ្រាប់មីន គ្រាប់រំសេវនិចល និងគ្រាប់សិប្បនិម្មិតសម្រាប់ហាត់រៀន មិនត្រូវផ្ទុក ជាមួយរថយន្តដែលដឹកគ្រាប់រំសេវពិតប្រាកដឡើយ លើកលែងតែពេលណាដែលកាលៈទេសៈមិនអនុញ្ញាត ។

## ៤.ការដោះបំបែកគ្រាប់មីន និង គ្រាប់រំសេវ

ប្រតិបត្តិករដោះមីន មិនគួរដោះបំបែក កែច្នៃ ឬ រុះរើគ្រាប់មីន និងគ្រាប់រំសេវឡើយ វៀរលែងតែ ធ្វើដើម្បីត្រួតពិនិត្យ ការកែប្រែ ឬ ការកំទេចចោល ដោយអនុលោមទៅតាមនីតិវិធីបច្ចេកទេស ដែលសមស្រប។

នីតិវិធីបច្ចេកទេសសម្រាប់ដោះបំបែក ឬ កែប្រែគ្រាប់មីន និងគ្រាប់រំសេវដែលនៅមានឥទ្ធិពល ឲ្យទៅជាគ្រាប់មីននិចល ឬ គ្រាប់សិប្បនិម្មិតសម្រាប់ហាត់រៀន ត្រូវរៀបចំដោយបុគ្គលិកកំទេចគ្រាប់យុទ្ធភ័ណ្ឌ ដែលមានលក្ខណសម្បត្តិសមស្រប ។

រាល់ការអនុញ្ញាតអោយធ្វើការដោះបំបែក ឬ ការកែប្រែគ្រាប់មីនដែលនៅមានឥទ្ធិពល និងរំសេវផ្ទុះ ឲ្យទៅជានិចល ឬ ការធ្វើគ្រាប់សិប្បនិម្មិតសម្រាប់ហាត់រៀន អាចធ្វើទៅបានតែចំពោះបុគ្គលិក ដែលមានបច្ចេកទេសគ្រប់គ្រាន់ផ្នែកកំទេចយុទ្ធភ័ណ្ឌប៉ុណ្ណោះ ។ ប្រតិបត្តិការបែបនេះ ពោរពេញទៅដោយគ្រោះថ្នាក់កម្រិតខ្ពស់ ដូចនេះការអនុញ្ញាតសម្រាប់ធ្វើសកម្មភាពបែបនេះ ត្រូវទទួលខុសត្រូវដោយអ្នកគ្រប់គ្រងកម្មវិធីជាតិ ឬ អ្នកដែលមានឋានៈប្រហាក់ប្រហែល នៅក្នុងប្រតិបត្តិករដោះមីន។

**កំណត់ចំណាំៈ**

គ្រាប់មីន និង គ្រាប់រំសេវនិចលសម្រាប់ហាត់រៀន អាចមានជាស្រេចនៅលើទីផ្សារពាណិជ្ជកម្ម ។ គ្រាប់ទាំងនេះផលិតឡើងពីសមាសភាព ដែលពុំមានរំសេវផ្ទុះ ឬ សម្រាប់គោលបំណងជាក់លាក់ ។ គ្រាប់ទាំងនេះ គួរប្រើប្រាស់ជាជម្រើសទីមួយ ។ ចំពោះគ្រាប់មីន និងគ្រាប់រំសេវនិចល ដែលផលិតក្នុងស្រុកសម្រាប់ការហាត់រៀន គួរប្រើជាមធ្យោបាយចុងក្រោយបំផុត ។

## ៥.ការដាក់ផ្លាកសញ្ញាសម្គាល់គ្រាប់មីន និង គ្រាប់រំសេវនិចល

គ្រាប់មីន និងគ្រាប់រំសេវនិចល ឬ គ្រាប់សិប្បនិម្មិតផ្សេងៗទៀតសម្រាប់ហាត់រៀន ត្រូវដាក់ផ្លាកសញ្ញាសម្គាល់ឲ្យបានច្បាស់លាស់ នៅគ្រប់ជ្រុងទាំងអស់ថា " ***គ្រាប់និចល*** " ឬ " ***គ្រាប់សម្រាប់ហាត់រៀន*** " ជាភាសាខ្មែរ និងភាសាអង់គ្លេស ។ ធ្វើដូច្នេះ ដើម្បីធានាថា គ្រាប់ទាំងនេះអាចសម្គាល់បានយ៉ាងច្បាស់លាស់ ពីគ្រប់ជ្រុងទាំងអស់ និងដើម្បីជៀសវាងការភ័ន្តច្រឡំដោយចៃដន្យ ឬ ដោយមិនប្រុងប្រយ័ត្ន ដោយប្រតិបត្តិការដោះមីន ឬ ដោយការធ្វើឲ្យមានសុវត្ថិភាព។

គ្រាប់មីន និងគ្រាប់រំសេវនិចល ឬ ការធ្វើគ្រាប់សិប្បនិម្មិតផ្សេងៗ សម្រាប់ការហាត់រៀន ត្រូវដាក់ផ្លាកសញ្ញាសម្គាល់ ដោយចុះលេខ លំដាប់ អនុវត្តតាមទម្រង់ដូចខាងក្រោមៈ

ABC/1234/01

( ប្រតិបត្តិករដោះមីន / លេខលំដាប់ / ឆ្នាំផលិត / ទិញ )

នៅពុំទាន់មានស្តង់ដាអន្តរជាតិ ដើម្បីកំណត់សម្គាល់ពណ៌តួគ្រាប់រំសេវ និងរំសេវផ្ទុះឡើយទេ ។ ហេតុដូចនេះ គេមិនអាចដាក់ចេញជាស្តង់ដា សម្រាប់កំណត់ពណ៌គ្រាប់មីន និងគ្រាប់រំសេវនិចល ឬគ្រាប់សិប្បនិម្មិតសម្រាប់ហាត់រៀនបានឡើយ វាអាចមានការច្រឡំ ។

បើសិនជាបុគ្គលណាម្នាក់សង្ស័យចំពោះគ្រាប់មីន ឬ គ្រាប់យុទ្ធភ័ណ្ឌណាមួយ ត្រូវចាត់ទុកវាជាគ្រាប់មីន ឬ គ្រាប់យុទ្ធភ័ណ្ឌពិតប្រាកដ និងត្រូវសុំការណែនាំជាបន្ទាន់ពីអ្នកបច្ចេកទេសដោះមីន ឬ អ្នកជំនាញ ផ្នែកកំទេចគ្រាប់យុទ្ធភ័ណ្ឌ ។

## ៦.ការចុះបញ្ជី ការរាប់ចំនួនគ្រាប់មីន និងគ្រាប់រំសេវនិចលសម្រាប់ហាត់រៀន

ប្រតិបត្តិករដោះមីន ត្រូវរក្សាបញ្ជីគ្រាប់មីន គ្រាប់រំសេវនិចល ឬ គ្រាប់សិប្បនិម្មិតសម្រាប់ហាត់រៀន ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ខ្លួន ។ បញ្ជីឈ្មោះនេះ ត្រូវដាក់បញ្ចូលព័ត៌មានដូចខាងក្រោម:

ក)-លេខលំដាប់

ខ)-ប្រភេទគ្រាប់មីន ឬ យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

គ)-ទីតាំងបច្ចុប្បន្ន

ឃ)-លេខលំដាប់ ប័ណ្ណបញ្ជាក់គ្រាប់ពុំមានរំសេវផ្ទុះ

ប្រតិបត្តិករដោះមីន ត្រូវរៀបចំប្រព័ន្ធកត់ត្រាឲ្យបានសមរម្យ ដើម្បីធានាការទទួលខុសត្រូវ និងការតាមដានចំពោះគ្រាប់មីន និងគ្រាប់រំសេវនិចល ដែលមានសម្រាប់ហាត់រៀន ។ ប្រព័ន្ធកត់ត្រានេះ ត្រូវផ្អែកលើចំនួនគ្រាប់ជាក់ស្តែង ។

## ៧.លិខិតបញ្ជាក់ពីគ្រាប់ដែលពុំមានរំសេវផ្ទុះ

មុននឹងទទួលគ្រាប់ដែលសន្មត់ថាជាគ្រាប់រំសេវនិចល ឬ គ្រាប់សិប្បនិម្មិតសម្រាប់ហាត់រៀន ត្រូវត្រួតពិនិត្យឲ្យបានហ្មត់ចត់ និង ច្បាស់លាស់ពីអ្នកបច្ចេកទេសផ្នែកកំទេចយុទ្ធភ័ណ្ឌ ដែលមានលក្ខណសម្បត្តិសមស្រប ដើម្បីធានាថា គ្រាប់នោះពុំមានរំសេវផ្ទុះ រំសេវផាយរ៉ូទិចនិច រំសេវបង្ហៀរទឹកភ្នែក វិទ្យុសកម្ម គីមីជីវសាស្ត្រ សារធាតុ ឬ សមាសភាពពុលផ្សេងៗទៀត។ អ្នកបច្ចេកទេសផ្នែកកំទេចយុទ្ធភ័ណ្ឌ ត្រូវធានា ថាការដាក់ផ្លាកសញ្ញាសម្គាល់គ្រាប់រំសេវទាំងអស់ (ការកំណត់សម្គាល់ផ្នែកគ្រោះថ្នាក់ លេខកូដគ្រោះថ្នាក់ លេខលំដាប់មុនៗ រូបសញ្ញាអង្គការសហប្រជាជាតិ ។ល។) ដែលសំដៅលើសញ្ញាសម្គាល់ពីមុន ដែលបញ្ជាក់ថា ជាគ្រាប់មីនពិតប្រាកដនោះ ត្រូវបានយកចេញ ឬ លុបបំបាត់ចោល ។

ពេលនោះ អ្នកបច្ចេកទេសផ្នែកកំទេចគ្រាប់យុទ្ធភ័ណ្ឌ ត្រូវចេញប័ណ្ណបញ្ជាក់សម្រាប់គ្រាប់មីនដែល ពុំមានរំសេវផ្ទុះ ដោយបញ្ជាក់នូវព័ត៌មាន ដូចខាងក្រោម:

ក)-លេខលំដាប់ (នេះគឺជាការតម្រូវឲ្យមានភាពងាយស្រួលនៃកិច្ចការរដ្ឋបាល ដូចគ្នាទៅនឹងលេខលំដាប់ នៅក្នុងប្រយោគទី ៥ដែរ)

ខ)-កាលបរិច្ឆេទ

គ)-ឈ្មោះអ្នកបច្ចេកទេសផ្នែកកំទេចយុទ្ធភ័ណ្ឌ ដែលធ្វើការត្រួតពិនិត្យ

ឃ )-ពិពណ៌នាសង្ខេបពីគ្រាប់
ង )-សេចក្តីបញ្ជាក់អំពីគ្រាប់ដែលពុំមានរំសេវផ្ទុះ។

**កំណត់ចំណាំៈ**

សេចក្តីបញ្ជាក់ខាងក្រោម ត្រូវសរសេរជាភាសាជាតិថាៈ
" ខ្ញុំសូមបញ្ជាក់ថា ខ្ញុំបានធ្វើការត្រួតពិនិត្យ និងពិនិត្យយ៉ាងច្បាស់លាស់ ចំពោះគ្រាប់ដែលបាន ចុះបញ្ជីនៅក្នុងប័ណ្ណបញ្ជាក់ និងសូមអះអាងថា គ្រាប់ទាំងអស់នេះពុំមានរំសេវផ្ទុះ ផាយរ៉ូទិចនិច រំសេវបង្ហៀរទឹកភ្នែក វិទ្យុសកម្ម គីមីជីវសាស្ត្រ សារជាតុ ឬ សមាសភាពពុល ផ្សេងៗទៀតឡើយ ។ ខ្ញុំក៏សូមបញ្ជាក់ផងដែរថា គ្រាប់រំសេវដែលមានសញ្ញាសម្គាល់ពីមុនៗត្រូវបានយកចេញ ឬ លុបចោល ហើយគ្រាប់ទាំងនោះ ត្រូវបានដាក់សញ្ញាសម្គាល់ថ្មីថាជាគ្រាប់និចល ឬ គ្រាប់សម្រាប់ហាត់រៀន។ ខ្ញុំជឿជាក់ថា គ្រាប់ទាំងនេះ មានសុវត្ថិភាពសម្រាប់ការហាត់រៀន ការដាក់តាំង ឬ ការហ្វឹកហ្វឺន " ។

ច )-ហត្ថលេខារបស់អ្នកបច្ចេកទេសផ្នែកកំទេចយុទ្ធភ័ណ្ឌ ដែលធ្វើការត្រួតពិនិត្យ។ ប្រតិបត្តិករដោះមីន ត្រូវថែរក្សាបញ្ជីឈ្មោះនៃគ្រាប់ពុំមានរំសេវផ្ទុះទាំងអស់ ដែលមានប័ណ្ណបញ្ជាក់ត្រឹមត្រូវ។

***

## **បម្រាម**

បើសិនជនណាម្នាក់ មានការសង្ស័យចំពោះគ្រាប់មីន គ្រាប់រំសេវ ឬ យុទ្ធភ័ណ្ឌណាមួយ ត្រូវចាត់ទុកថា គ្រាប់ទាំងនោះជាគ្រាប់ដែលនៅមានអានុភាពផ្ទុះបាន ហើយត្រូវសុំការណែនាំជាបន្ទាន់ ពីអ្នកបច្ចេកទេសដោះមីន ឬ អ្នកបច្ចេកទេស ផ្នែកកំទេចគ្រាប់យុទ្ធភ័ណ្ឌ ។

***